**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥៥៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- លិខិតលេខ ៦៧៨ សជណ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៦៩៦៧ កសក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១៖**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦៦០,៩៨៣៧ (ប្រាំមួយរយហុកសិបក្បៀសប្រាំបួនពាន់ប្រាំបីរយសាមសិបប្រាំពីរ) ហិកតា ដែលមានទីតាំងស្ថិតនៅឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី របស់ក្រុមហ៊ុន គិរីអភិវឌ្ឍន៍ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច និងប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុចំនួន ០៣ប័ណ្ណ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តរតនគិរី។

**មាត្រា២៖**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# គំនូសបង្ហាញទីតាំងដីស្នើសុំចុះបញ្ជីជាកម្មសិទ្ធិរបស់រដ្ឋ ក្នុងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ធីរី អភិវឌ្ឍន៍

ស្ថិតនៅឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី

**សំគាល់**

- ចំណុចព្រំដី
- ព្រំក្រុមហ៊ុន សម្បទានដីសេដ្ឋកិច្ច
- ដីស្នើសុំ ជាក្បាលដី (៦៦០.៩៨ ហ.ត)
- តំបន់ទ្រនាប់អូរ (៨៥.៧៩ ហ.ត)
- ដីប្រជាពលរដ្ឋ (៦.៩៧ ហ.ត)
- តំបន់ព្រៃក្រាស់ (២៥.៤៦ ហ.ត)
- តំបន់ប្រលាយ (៧៧.៣៧ ហ.ត)
- ដី១ (៧.៣០ ហ.ត)

0 0.5 1 km

តារាងនិយាមកាចំណុចព្រំដី ជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច
ឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី

Projection: UTM, Zone 48N; Datum WGS 84

| Point ID | Northing (m) | Easting (m) |
|---|---|---|
| A | 1532600.503 | 698356.820 |
| B | 1533937.960 | 698255.014 |
| C | 1534373.396 | 698003.684 |
| D | 1534837.324 | 697371.581 |
| E | 1535918.608 | 699015.986 |
| F | 1535914.230 | 700035.510 |
| G | 1534187.505 | 700560.818 |
| H | 1533865.506 | 701506.818 |
| I | 1532022.938 | 701325.263 |
| J | 1533192.504 | 699354.819 |
| K | 1533197.503 | 699012.820 |




រតនគិរី, ថ្ងៃទី...... ខែ...... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគិរី
ទឹម ស៊ីណាត

បានឃើញ និងឯកភាព
រតនគិរី, ថ្ងៃទី...០៤... ខែ...... ឆ្នាំ២០១៧
អភិបាល នៃគណៈអភិបាលខេត្តរតនគិរី
ថង សាវុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី ខេត្តរតនគិរី
លេខៈ ០២៧/១៧

**សូមគោរពជូន**

**ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីលទ្ធផលក្រុមការងារចុះវាស់វែង និងសិក្សាផលប៉ះពាល់ក្នុងទីតាំងសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **គីរី អភិវឌ្ឍន៍** ។

**យោង** ÷ របាយការណ៍ស្តីពីការកំណត់ព្រំ និងវាស់វែងដី ដើម្បីចុះបញ្ជីដី នៃដីឯកជនរបស់រដ្ឋ ក្នុងដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន គីរីអភិវឌ្ឍន៍។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត** មេត្តាជ្រាបថាៈ អនុវត្តតាមលិខិតបង្គាប់ការរបស់សាលាខេត្តរតនគិរី ដោយមានការចូលរួមពីមន្ទីរ ស្ថាប័នពាក់ព័ន្ធ ក្រុមការងារដីរដ្ឋថ្នាក់ស្រុក អាជ្ញាធរដែនដី ប្រជាពលរដ្ឋ ក្រុមការងារបានចុះទៅដល់ទីតាំងសម្បទានដីសេដ្ឋកិច្ចដាក់ស្តែងចុចយកចំណុចនិយាមកា បង្គោលព្រំដីនីមួយៗ ពិនិត្យវាស់វែងផលប៉ះពាល់ដីស្រែ-ចំការ និងផលប៉ះពាល់ផ្សេងៗទៀត ដោយប្រើប្រាស់ឧបករណ៍ GPS Garmin 62s។

លទ្ធផលនៃការវាស់វែង មន្ទីរបានរៀបចំប្រជុំក្រុមការងារវាលដើម្បីពិនិត្យ ពិភាក្សា ដោយបានទទួលបានលទ្ធផលដូចខាងក្រោម ៖

| តារាងនិយាមកា ចំណុចព្រំដី ជាកម្មវត្ថុនៃ សម្បទានដីសេដ្ឋកិច្ច | | |
|---|---|---|
| ឃុំភ្នំកុក ស្រុកវើនសៃ ខេត្តរតនគិរី | | |
| Projection UTM, Zone 48N; Datum WGS 1984 | | |
| Point ID | Northing (m) | Easting (m) |
| A | 1532600.503 | 698356.820 |
| B | 1533937.960 | 698255.014 |
| C | 1534373.396 | 698003.684 |
| D | 1534837.324 | 697371.581 |
| E | 1535918.608 | 699015.986 |
| F | 1535914.230 | 700035.510 |
| G | 1534187.505 | 700560.818 |

| | | |
|---|---|---|
| H | 1533865.506 | 701506.818 |
| I | 1532022.938 | 701325.263 |
| J | 1533192.504 | 699354.819 |
| K | 1533197.503 | 699012.820 |

ទំហំផ្ទៃដី នៃផលប៉ះពាល់ និងក្បាលដីស្នើសុំចុះបញ្ជីដី

| ប្រភេទដី | ទំហំ (ហិកតា) |
|---|---|
| តំបន់ព្រៃក្រាស់ៗ | ២៤,៤៦ |
| តំបន់ទ្រនាប់អូរ | ៨៥,៧៩ |
| ដីប្រជាពលរដ្ឋតាមបទបញ្ជា០១ របស់រាជរដ្ឋាភិបាល | ៧,៣០ |
| ដីប្រជាពលរដ្ឋផ្សេងទៀត | ៦,៥៧ |
| តំបន់ប្រសាទ | ៧៧,៣៧ |
| ផ្ទៃដីដែលមិនបានដាំដុះ | ៨០,០១ |
| ផ្ទៃដីស្នើសុំចុះបញ្ជី | ៦៦០,៩៨ |

ដូច្នេះផ្ទៃដីឯកជនរបស់រដ្ឋ ដែលស្នើសុំចុះបញ្ជីដី ក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **តឺរី អភិវឌ្ឍន៍** មានចំនួន ០៣ ក្បាលដី ដែលមានទំហំសរុប **៦៦០,៩៨** ហិកតា។

អាស្រ័យដូចបានគោរពជំរាបជូនខាងលើ សូម **ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រតនគិរី, ថ្ងៃទី...០៥... ខែ...[illegible]..... ឆ្នាំ២០១៧

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**

**និងសុរិយោដី ខេត្តរតនគិរី**

ងិម សុវណ្ណារ៉ាត

**បានឃើញ និងឯកភាព**

**អភិបាលខេត្ត និងជាប្រធានអង្គប្រជុំ**

ថង សាវុន